## ៧. ការពិនិត្យតាមដាន និង ការពិនិត្យឡើងវិញលើការបំពេញការងារតាមវិស័យផ្តែកលើលទ្ធផល

### ៧.១ ការកែលំអការពិនិត្យតាមដានតាមវិស័យផ្តោតលើលទ្ធផល

បទពិសោធន៍ដ៏សំខាន់នៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំកន្លងមក គឺតម្រូវអោយកំណត់អាទិភាព និងសម្រួលម៉ាទ្រិកសកម្មភាពគោលនយោបាយ និងទិសដៅទាំងឡាយ ដើម្បីពង្រឹងចំណុចផ្តោតនៃរបៀបវារៈកំណែទម្រង់ ។ បទពិសោធន៍មួយទៀតគឺ ព្យាករណ៍ពីពេលវេលាចាំបាច់សម្រាប់ប្រែក្លាយសកម្មភាពគោលនយោបាយ ឱ្យទៅជាផលសម្រេចគោលនយោបាយ តាមមូលដ្ឋានប្រចាំឆ្នាំនីមួយៗ ។ ដូច្នេះ ការកំណត់ចំណុចដៅគោលនយោបាយ និងយុទ្ធសាស្ត្រ បានបង្ហាញពីស្មារតី និងមហិច្ឆតានៃការកែទម្រង់វិស័យអប់រំ ហើយនឹងត្រូវបានប្រើជាចំណុចគោល ដើម្បីវាស់ស្ទង់និន្នាការនៃការបំពេញការងារវិស័យអប់រំ ។

ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០០១-០៥ និងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០០៤-០៨ បានដាក់បញ្ចូលអាំងឌីកាទ័របំពេញការងារគោលនយោបាយមួយចំនួនដែលទាក់ទងនឹងវិធានការនានា ដើម្បីសម្រេចសមធម៌នៃការចូលរៀន ការកែលំអគុណភាព និងប្រសិទ្ធភាពនៃសេវាអប់រំ ព្រមទាំងការអភិវឌ្ឍស្ថាប័ន និងការកសាងសមត្ថភាពដើម្បីអនុវត្តវិមជ្ឈការការងារអប់រំ ។ ក្របខ័ណ្ឌពិនិត្យតាមដានការបំពេញការងារដែលបានកែលំអនៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០០៦-១០ នឹងរួមបញ្ចូលនូវការកែប្រែមួយចំនួនដែលទាក់ទងនឹង ១) អាំងឌីកាទ័រនៃការចូលរៀនក្នុងការបណ្តុះបណ្តាលជំនាញក្រៅប្រព័ន្ធ ២) អាំងឌីកាទ័រគុណភាព និងប្រសិទ្ធភាពទាក់ទងនឹងកម្មវិធីចូលរៀនឡើងវិញ លក្ខណៈសម្បត្តិរបស់គ្រូបង្រៀន និងការពង្រាយគ្រូ ទិដ្ឋភាពនៃការបំពេញការងាររបស់គ្រឹះស្ថានសិក្សា និង ការសិក្សារបស់សិស្ស ៣) អាំងឌីកាទ័រអភិវឌ្ឍន៍ស្ថាប័នដែលទាក់ទងទៅនឹងកិច្ចបញ្ជិការគណនេយ្យ និងការអនុវត្តសវនកម្មនៅតាមអង្គភាពគ្រប់គ្រងថវិកា ព្រមទាំងការអភិវឌ្ឍមន្ត្រីអប់រំ ។ តារាងម៉ាទ្រិកគោលនយោបាយនៃការពិនិត្យតាមដានដែលបានកែលំអរួច មានបង្ហាញនៅក្នុងតារាងខាងក្រោមនេះ :

## តារាងទី ៥ ៖ ម៉ាទ្រិកការពិនិត្យតាមដានគោលនយោបាយនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ

| វិសាលភាព | អាំងឌីកាទ័រសំខាន់ៗ |
|---|---|
| **១- ការចូលរៀនប្រកបដោយសមធម៌** *(គិតទាំងយេនឌ័រ)* | ➢ និន្នាការនៃការចុះឈ្មោះចូលរៀនថ្នាក់ជាតិ ខេត្ត-ក្រុង និង ស្រុក-ខ័ណ្ឌ<br>➢ តុល្យភាពនៃការចុះឈ្មោះចូលរៀននៅទីក្រុង-ជនបទ និងយេនឌ័រ<br>➢ ចំនួនសិស្សដែលមកពីគ្រួសារក្រីក្របំផុត<br>➢ ចំនួនសាលារៀននៅបឋមសិក្សាមិនគ្រប់កំរិតថ្នាក់<br>➢ អត្រាឡើងថ្នាក់នៅកម្រិតអប់រំមូលដ្ឋាន<br>➢ អត្រាត្រួតថ្នាក់នៅកម្រិតអប់រំមូលដ្ឋាន<br>➢ អត្រាពិតចូលរៀនថ្មីនៅថ្នាក់ទី ១<br>➢ ទិដ្ឋភាពនៃការចុះឈ្មោះចូលរៀននៅឧត្តមសិក្សា<br>➢ ការចុះឈ្មោះចូលរៀននៅសាលាគរុកោសល្យ |
| **២- គុណភាព និង ប្រសិទ្ធភាពនៃសេវាអប់រំ** | ➢ ស្តង់ដាការសិក្សារបស់សិស្សកម្រិតបឋមសិក្សាដែលបានជ្រើសរើស នៅថ្នាក់ទី ៣ និង ទី ៦ នៅមធ្យមសិក្សាបឋមភូមិថ្នាក់ទី ៩ និងនៅមធ្យមសិក្សាទុតិយភូមិថ្នាក់ទី ១២<br>➢ លទ្ធភាពនៃសម្ភារសិក្សា និងគ្រូបង្រៀនដែលបានទទួលការបណ្តុះបណ្តាល<br>➢ ផលធៀបសិស្ស-គ្រូ<br>➢ សាលាកុមារមេត្រីគ្របដណ្តប់នៅតាមខេត្ត-ក្រុង<br>➢ លទ្ធភាពស្តង់ដាគុណភាពនៅគ្រប់កំរិត<br>➢ ការកំណត់ប៉ុស្តិ៍គ្រូបង្រៀននៅតំបន់ដាច់ស្រយាលដែលជួបការលំបាក<br>➢ ចំនួនសិស្សចូលរៀនឡើងវិញនៅថ្នាក់ទី ៣-៩<br>➢ សមាមាត្រ/ចំនួនគ្រូបង្រៀនដែលមានកម្រិតវប្បធម៌ថ្នាក់ទី ១០-១២ ឬខ្ពស់ជាងនេះ<br>➢ វិសាលភាពនៃសម្ភាររូបវ័ន្តផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងព័ត៌មានសារគមនាគមន៍ |
| **៣- ការអភិវឌ្ឍស្ថាប័ន និង ការកសាងសមត្ថភាព** | ➢ បរិមាណ និងចំណែកថវិកាសម្រាប់វិស័យអប់រំ<br>➢ បំណែងចែកថវិកាសម្រាប់ការចំណាយលើការអប់រំមូលដ្ឋាន<br>➢ ទិដ្ឋភាពនៃចំណាយ និងការបើកផ្តល់សាច់ប្រាក់សម្រាប់កម្មវិធីអាទិភាព<br>➢ វិសាលភាពនៃប្រព័ន្ធសវនកម្មផ្ទៃក្នុង<br>➢ ផលធៀបនៃចំណាយ និងការបែងចែកថវិកាសម្រាប់បៀវត្ស និងមិនមែនបៀវត្ស<br>➢ ភាគរយគ្រូបង្រៀនដែលមានលក្ខណៈសម្បត្តិទទួលប្រាក់រង្វាន់<br>➢ អត្រាពង្រាយបុគ្គលិកបង្រៀន និងបុគ្គលិកមិនបង្រៀន |

| | |
|---|---|
| | ➢ សមត្ថភាពប្រតិបត្តិការរបស់អង្គភាពគ្រប់គ្រងថវិកា<br>➢ លទ្ធផលរបស់ក្រសួងដែលបានពីកម្មវិធីបណ្តុះបណ្តាលផ្សេងៗ<br>➢ ចំនួនគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ/ឯកជនដែលមានការទទួលស្គាល់<br>➢ ការចុះឈ្មោះចូលរៀននៅគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ/ឯកជនដែលមានការទទួល ស្គាល់ |

ចំណុចដៅនៃការបំពេញការងារមួយចំនួន ត្រូវបានកំណត់នៅក្នុងតារាងម៉ាទ្រិកបំពេញការងារវិស័យអប់រំ ដែលបង្ហាញអំពីចំណុចគោលសំខាន់ៗ ក្នុងរយៈពេល ២០០៦-២០១០ (សូមមើលឧបសម្ព័ន្ធទី ២) ។

ដំណើរការពិនិត្យតាមដានផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០០៦-២០១០ ត្រូវបានរៀបចំឡើង ដើម្បីពង្រឹងទំនាក់ទំនងរវាងយុទ្ធសាស្ត្រអភិបាលកិច្ច និងគណនេយ្យភាព ។ ដូច្នេះ ក្រសួងអប់រំ យុវជន និងកីឡា នឹងផ្តល់របាយការណ៍ កាន់តែជាក់លាក់មួយចំនួនទៅឱ្យអ្នកពាក់ព័ន្ធនានា រួមមាន ក) របាយការណ៍ប្រចាំឆ្នាំជូនទៅរដ្ឋសភា ខ) របាយការណ៍បំពេញការងារវិស័យអប់រំរបស់ខេត្ត-ក្រុង គ) របាយការណ៍ស្តីពីការរីកចម្រើននៃកម្មវិធីនីមួយៗ ឃ) របាយការណ៍បំពេញការងាររបស់នាយកដ្ឋាននៅរដ្ឋបាលកណ្តាល ង) របាយការណ៍សិក្សាស្រាវជ្រាវពីប្រតិបត្តិការសម្រាប់ប្រើប្រាស់ពិសេស និង ច) របាយការណ៍ប្រចាំឆ្នាំស្តីពីសវនកម្មផ្ទៃក្នុងទៅលើអង្គភាពគ្រប់គ្រងថវិការបស់សាលារៀន និងកម្មវិធីនានា ។

ក្រសួងអប់រំ យុវជន និងកីឡាទទួលស្គាល់ថា ការពិនិត្យតាមដានផែនការយុទ្ធសាស្ត្រវិស័យអប់រំប៉ុន្មានឆ្នាំកន្លងមក នៅមានកម្រិត ជាពិសេសមិនបានលើកឡើងអំពីស្តង់ដានៃការបំពេញការងាររបស់សាលារៀន និងការសិក្សារបស់សិស្សទេ ។ ការដាក់អោយអនុវត្តប័ណ្ណរាយការណ៍របស់សាលារៀន និងការធ្វើតែសទូទាំងប្រទេសចំពោះសិស្សនៅតាមកម្រិតថ្នាក់ដែលបានជ្រើសរើស នឹងអាចដោះស្រាយបញ្ហានេះបាន ។ ក្រសួងអប់រំ យុវជន និងកីឡា នឹងផ្សព្វផ្សាយព័ត៌មានជាសាធារណៈអំពីស្តង់ដាបំពេញការងាររបស់សាលារៀន និងការសិក្សារបស់សិស្ស ដើម្បីជាព័ត៌មានដល់មាតាបិតាសិស្ស និងអ្នកធ្វើសេចក្តីសម្រេចចិត្តដទៃទៀត ព្រមទាំងពង្រឹងការចូលរួមរបស់អ្នកពាក់ព័ន្ធ ។

ប្រព័ន្ធពិនិត្យតាមដានការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ផ្អែកលើអង្គភាពទទួលខុសត្រូវ មានដូចខាងក្រោម :

- ❑ ***ការពិនិត្យតាមដានការអនុវត្ត*** : ដោយមន្ត្រីថ្នាក់ស្រុក-ខ័ណ្ឌ គណៈកម្មការទ្រទ្រង់សាលារៀន និងគណៈកម្មាការជាតិអប់រំសម្រាប់ទាំងអស់គ្នាឃុំ-សង្កាត់ ។

- ***ការពិនិត្យតាមដានការរីកចម្រើនរបស់កម្មវិធី*** : ដោយមន្ទីរអប់រំ យុវជន និងកីឡាខេត្ត-ក្រុង ជាពិសេស ការិយាល័យផែនការ ការិយាល័យអធិការកិច្ច ការិយាល័យហិរញ្ញវត្ថុខេត្ត-ក្រុង និងនាយកដ្ឋានជំនាញ ក្រោមឱវាទក្រសួងសម្រាប់កម្មវិធីជាអាទិភាព និងកម្មវិធីដទៃទៀតរបស់ខ្លួន ។
- ***ការពិនិត្យតាមដានការបំពេញការងារវិស័យ*** : ដោយអធិការដ្ឋានអប់រំ សហការជាមួយនាយកដ្ឋានផែនការ គណៈកម្មការជាតិអប់រំសម្រាប់ទាំងអស់គ្នា នាយកដ្ឋានជំនាញ និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួង ។
- ***ការពិនិត្យតាមដានលើផលប៉ះពាល់កម្មវិធី*** : ដោយនាយកដ្ឋានផែនការ សហការជាមួយនាយកដ្ឋានរបស់ក្រសួង និងអង្គភាពពាក់ព័ន្ធមួយចំនួន ។
- ***សវនកម្មការបំពេញការងាររបស់ប្រព័ន្ធ*** : ដោយអធិការដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ នាយកដ្ឋានសវនកម្ម និង អាជ្ញាធរជាតិសវនកម្ម ។

ការរកឃើញទាំងឡាយក្នុងពេលធ្វើការពិនិត្យឡើងវិញកម្មវិធីគាំទ្រវិស័យអប់រំឆ្នាំ ២០០៥-២០០៩ មានដូចជាសមត្ថភាពក្នុងការកសាងផែនការ ការគ្រប់គ្រងព័ត៌មានស្តីពីការបំពេញការងារនៅមានកម្រិត ម៉្យាងទៀតការផ្តល់របាយការណ៍បំពេញការងារមិនទាន់ពេលវេលា និងពុំមានលក្ខណៈពេញលេញ ជាពិសេសរបាយការណ៍ហិរញ្ញវត្ថុ ។ ដូចនេះ ជាអាទិភាព គឺត្រូវពង្រឹង និងពង្រីកការកសាងសមត្ថភាពក្នុងការកសាងផែនការ ការគ្រប់គ្រងប្រព័ន្ធព័ត៌មានផ្អែកលើបច្ចេកវិទ្យាព័ត៌មាន នៅគ្រប់កម្រិតថ្នាក់ ជាពិសេសនៅថ្នាក់ស្រុក-ខ័ណ្ឌ សាលារៀនតំបន់ដាច់ស្រយាល តំបន់ព្រំដែន និង តំបន់ជួបការលំបាក ។

## ៧.២ ការពង្រឹងដំណើរការពិនិត្យឡើងវិញរួមគ្នាការបំពេញការងារវិស័យអប់រំប្រចាំឆ្នាំ

នៅមុនពេលប្រារព្ធកិច្ចពិនិត្យឡើងវិញកម្មវិធីគាំទ្រវិស័យអប់រំប្រចាំឆ្នាំ និងការពិនិត្យឡើងវិញលើផែនការយុទ្ធសាស្ត្រវិស័យអប់រំ ក្រសួងអប់រំ យុវជន និងកីឡា ចាំបាច់ត្រូវរៀបចំរបាយការណ៍បំពេញការងារវិស័យអប់រំប្រចាំឆ្នាំ និងធ្វើការពិនិត្យតាមដានការបំពេញការងារវិស័យរួមគ្នាប្រកបដោយតម្លាភាព ។ ក្រសួងអប់រំ យុវជន និងកីឡា ទទួលស្គាល់ថា វត្ថុបំណងសំខាន់នៃដំណើរការពិនិត្យឡើងវិញ គឺដើម្បីដកស្រង់បទពិសោធន៍ពីគ្នាទៅវិញទៅមក និងដើម្បីកែសម្រួលគោលនយោបាយ និងយុទ្ធសាស្ត្ររបស់ខ្លួនអោយបានសមស្របនឹងការជាក់ស្តែង ។ នេះគឺជាឱកាសដើម្បីផ្តល់វេទិកាក្នុងការចូលរួមសហការកសាងផែនការសម្រាប់ពេលអនាគត ពីសំណាក់អ្នកផ្តល់ជំនួយ អង្គការក្រៅរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធដទៃទៀត ។ ដូច្នេះ ដំណើរការពិនិត្យឡើងវិញផែនការយុទ្ធសាស្ត្រវិស័យអប់រំ នឹងបន្តសម្របសម្រួលគោលវិធីដែលអនុវត្តនៅក្នុងកំណែទម្រង់កម្មវិធី

វិកិលដែលមានលក្ខណៈទន់ភ្លន់មួយ ។ បន្ថែមពីលើការពិនិត្យឡើងវិញវិស័យអប់រំប្រចាំឆ្នាំ ក្រសួងអប់រំ យុវជន និងកីឡា ក៏បានបន្តពង្រឹងយន្តការពិគ្រោះយោបល់ផ្សេងៗទៀតរួមមាន :

- ការពិគ្រោះយោបល់របស់ក្រុមការងារបច្ចេកទេសចំរុះសម្រាប់វិស័យអប់រំ យុវជន និងកីឡា (Joint Technical Working Group in Education) ដែលធ្វើឡើងរៀងរាល់ពីរខែម្តងជាមួយតំណាងអ្នកផ្តល់ជំនួយ និង អង្គការក្រៅ រដ្ឋាភិបាល ដើម្បីផ្តល់របាយការណ៍ពិនិត្យតាមដានការរីកចម្រើនលើបញ្ហាសំខាន់ៗ និង ឯកភាពលើសកម្មភាពចាំបាច់នានា ។

- ពង្រឹងកិច្ចសម្របសម្រួលជាមួយថ្នាក់ដឹកនាំរាជរដ្ឋាភិបាល និងអ្នកផ្តល់ជំនួយតាមរយៈរបាយការណ៍ រីកចម្រើនរបស់វិស័យអប់រំ និងកិច្ចប្រជុំជាមួយក្រុមការងារវិស័យសង្គមកិច្ច និងក្រុមប្រឹក្សាជាតិសម្រាប់ អភិវឌ្ឍន៍សង្គម ជាផ្នែកមួយនៃការរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ ។

- ការកសាងសមត្ថភាពបន្ថែមដល់នាយកដ្ឋានផែនការ គឺមានសារៈសំខាន់ជាទីបំផុត ជាពិសេសការរៀបចំ របាយការណ៍មួយចំនួនដូចជា : ១) របាយការណ៍បំពេញការងារប្រចាំឆ្នាំរបស់វិស័យអប់រំ ២) របាយ-ការណ៍ប្រចាំឆ្នាំរបស់អ្នកផ្តល់ជំនួយ និង ៣) របាយការណ៍ប្រចាំឆ្នាំរបស់អង្គការក្រៅរដ្ឋាភិបាល ។

- គណៈកម្មការជាតិអប់រំសម្រាប់ទាំងអស់គ្នា ក៏ជាអង្គភាពមួយដែលជួយពង្រឹងដំណើរការពិនិត្យតាមដាន ការបំពេញការងារវិស័យអប់រំអោយបានកាន់តែខ្លាំងក្លាថែមទៀត ។ គណៈកម្មការជាតិអប់រំសម្រាប់ ទាំងអស់គ្នា ត្រូវធ្វើរបាយការណ៍ប្រចាំឆ្នាំស្តីពីការអប់រំសម្រាប់ទាំងអស់គ្នា ដោយផ្តោតលើការសម្រប សម្រួលអន្តរក្រសួងសម្រាប់កម្មវិធីនីមួយៗ ដូចជាគាំពារកុមារតូច និងសកម្មភាពការងាររបស់ គណៈកម្មការអប់រំសម្រាប់ទាំងអស់គ្នានៅគ្រប់លំដាប់ថ្នាក់ ។ របាយការណ៍នេះ នឹងត្រូវដាក់បញ្ចូលទៅ ក្នុងរបាយការណ៍ស្តីពីការកសាងផែនការ និង អភិបាលកិច្ចអន្តរក្រសួងលើការបំពេញការងារវិស័យ ។ ក្រសួងអប់រំ យុវជន និងកីឡា នឹងពិនិត្យឡើងវិញលើការកែសម្រួលកាលវិភាគរបស់សន្និបាតអប់រំថ្នាក់ ជាតិ និងថ្នាក់ខេត្ត-ក្រុងប្រចាំឆ្នាំ ដើម្បីផ្សារភ្ជាប់ទៅនឹងដំណើរការពិនិត្យឡើងវិញកម្មវិធីគាំទ្រវិស័យ អប់រំ ។

បទពិសោធន៍ដែលទទួលបានពីការពិនិត្យឡើងវិញលើកម្មវិធីគាំទ្រវិស័យអប់រំក្នុងអំឡុងពេលប៉ុន្មានឆ្នាំ កន្លងមកនេះ បានផ្តល់ឱកាសដ៏ល្អដើម្បីពិភាក្សា និងចរចាជាមួយអ្នកផ្តល់ជំនួយ និងអង្គការក្រៅរដ្ឋាភិបាលស្តីពី កម្មវិធីជំនួយពីខាងក្រៅនាពេលបច្ចុប្បន្ន និងសម្រាប់ពេលអនាគត ។ ដូចនេះ ក្រសួងអប់រំ យុវជន និងកីឡា ស្នើឱ្យប្រើប្រាស់ដំណើរការពិនិត្យឡើងវិញលើកម្មវិធីគាំទ្រវិស័យអប់រំ ជាវេទិកាដើម្បីធ្វើការសម្របសម្រួល និង ធ្វើអោយមានភាពរលូនដល់ការបង្កើតជាកម្មវិធី និងការវាយតម្លៃរបស់អ្នកផ្តល់ជំនួយ និងអង្គការក្រៅរដ្ឋាភិបាល

នីមួយៗ ។ ការអនុវត្តបែបនេះ នឹងជួយកាត់បន្ថយចំណាយប្រតិបត្តិការ (Transactional Cost) សំខាន់ៗនៃការអនុវត្តកម្មវិធីដោយឡែកៗរបស់អ្នកផ្តល់ជំនួយ និង អង្គការក្រៅរដ្ឋាភិបាលនីមួយៗ ។

**ក្របខ័ណ្ឌអភិវឌ្ឍជាតិ**

- យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល – កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ សាធារណៈ
- កំណែទម្រង់រដ្ឋបាលសាធារណៈ – ការធ្វើវិមជ្ឈការការងារ - CMDGs, NSDP, EFA

**ផែនការយុទ្ធសាស្ត្រវិស័យ អប់រំ ២០០៦-១០**

អាទិភាពគោលនយោបាយ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ

| ការចូលរៀនប្រកបដោយសមធម៌ចំពោះសេវាអប់រំ | គុណភាព និងប្រសិទ្ធភាពសេវាអប់រំ | ការអភិវឌ្ឍស្ថាប័ន និងការកសាងសមត្ថភាពសម្រាប់ធ្វើវិមជ្ឈការ |
|---|---|---|
| - សេចក្តីថ្លែងពីគោលនយោបាយទូលំទូលាយ និងផលសម្រេចសំខាន់ៗ - ចំណុចដៅ និង យុទ្ធសាស្ត្រចម្បង | - សេចក្តីថ្លែងពីគោលនយោបាយទូលំទូលាយ និងផលសំរេចសំខាន់ៗ<br>- ចំណុចដៅ និងយុទ្ធសាស្ត្រចំបង | - សេចក្តីថ្លែងពីគោលនយោបាយទូលំទូលាយ និងផលសំរេចសំខាន់ៗ<br>- ចំណុចដៅ និងយុទ្ធសាស្ត្រចំបង |

**កម្មវិធីគាំទ្រវិស័យអប់រំ ២០០៦-១០**

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ក.ស.អ គុណភាព និង ប្រសិទ្ធភាពសេវា អប់រំ | **កម្មវិធីអាទិភាព** ការអប់រំកុមារតូច | **កម្មវិធីអាទិភាព** គុណភាព និង ប្រសិទ្ធភាពការអប់រំ បឋមសិក្សា | **កម្មវិធីអាទិភាព** ការចូលរៀន គុណភាព និង ប្រសិទ្ធភាពការអប់រំមធ្យមសិក្សាបឋមភូមិ | **កម្មវិធីអាទិភាព** ការចូលរៀន និង សមធម៌ការអប់រំ មធ្យមសិក្សា ទុតិយភូមិ | **កម្មវិធីអាទិភាព** គុណភាព និង ប្រសិទ្ធភាពការអប់រំ ឧត្តមសិក្សាសិក្សា | **កម្មវិធីអាទិភាព** ការបន្តអភិវឌ្ឍគ្រូ បង្រៀន | **កម្មវិធីអាទិភាព** សម្ភារសិក្សាគោល | **កម្មវិធីអាទិភាព** ការពង្រីកការអប់រំ ក្រៅប្រព័ន្ធ | **កម្មវិធីអាទិភាព** ការអភិវឌ្ឍយុវជន និងកីឡា | **កម្មវិធីអាទិភាព** ការពង្រឹងប្រព័ន្ធ ពិនិត្យតាមដាន | **កម្មវិធីអាទិភាព** អាហារូបករណ៍ សម្រាប់សិស្សក្រីក្រ នៅមធ្យមសិក្សា | កម្មវិធីអភិវឌ្ឍ សម្ភាររូបវ័ន្តអប់រំ | ការកសាងសមត្ថភាព និងអភិវឌ្ឍស្ថាប័ន |

**<u>សម្រាប់កម្មវិធីសកម្មភាពជាអាទិភាពនីមួយៗ និងកម្មវិធីអភិវឌ្ឍសម្ភាររូបវ័ន្តអប់រំ</u> :**

- វត្ថុបំណង និងយុត្តិកម្ម
- ចំណុចដៅ និងអាំងឌីកាទ័រសំខាន់ៗ
- យុទ្ធសាស្ត្រ និងវិសាលភាព
- កម្មវិធី និងសកម្មភាពសំខាន់ៗ
- ការគ្រប់គ្រង និងការពិនិត្យតាមដានកម្មវិធី
- ផែនការហិរញ្ញប្បទាន
- តម្រូវការនៃការកសាងសមត្ថភាព
- សកម្មភាពនៃគោលនយោបាយ

**កម្មវិធីសកម្មភាពជាអាទិភាព: ក.ស.អ**

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ក.ស.អ គុណភាព និង ប្រសិទ្ធភាពសេវា អប់រំ | ក.ស.អ ការអប់រំកុមារតូច | ក.ស.អ គុណភាព និង ប្រសិទ្ធភាពការអប់រំ បឋមសិក្សា | ក.ស.អ ការចូលរៀន គុណភាព និង ប្រសិទ្ធភាពការអប់រំមធ្យមសិក្សាបឋមភូមិ | ក.ស.អ ការចូលរៀន និង សមធម៌ការអប់រំ មធ្យមសិក្សា ទុតិយភូមិ | ក.ស.អ គុណភាព និង ប្រសិទ្ធភាពការអប់រំ ឧត្តមសិក្សាសិក្សា | ក.ស.អ ការបន្តអភិវឌ្ឍគ្រូ បង្រៀន | ក.ស.អ សម្ភារៈសិក្សាគោល | ក.ស.អ ការពង្រីកការអប់រំ ក្រៅប្រព័ន្ធ | ក.ស.អ ការអភិវឌ្ឍយុវជន និងកីឡា | ក.ស.អ ការពង្រឹងប្រព័ន្ធ ពិនិត្យតាមដាន | ក.ស.អ អាហារូបករណ៍ សំរាប់សិស្សក្រីក្រ នៅមធ្យមសិក្សា | កម្មវិធីអភិវឌ្ឍ សម្ភារៈ រូបវ័ន្តអប់រំ | ការកសាងសមត្ថភាព និងអភិវឌ្ឍស្ថាប័ន |